00660497

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 08 / 04 / 2011
ម៉ោង (Time/Heure): 14:30
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

E9/7/1/1/1/4

អង្គជំនុំជម្រះតុលាការកំពូល
Supreme Court Chamber
Chambre de la Cour Suprême

សំណុំរឿងលេខ: ០០១/១៨-កក្កដា-២០០៧-អ.វ.ត.ក/អ.ជ.ត.ក(០៣ និង០៥)
Case File/Dossier N°. 002/19-09-2007-ECCC/TC/SC (03 and 05)

នៅចំពោះមុខ៖

ចៅក្រម គង់ ស្រ៊ីម ប្រធាន
ចៅក្រម **Motoo NOGUCHI**
ចៅក្រម សោម សិរីវឌ្ឍ
ចៅក្រម **Agnieszka KLONOWIECKA-MILART**
ចៅក្រម ស៊ិន រិទ្ធ
ចៅក្រម **Chandra Nihal Jayasinghe**
ចៅក្រម យ៉ា ណារិន

កាលបរិច្ឆេទឯកសារ៖ ថ្ងៃទី០៨ ខែមេសា ឆ្នាំ២០១១
ភាសាដើម៖ ខ្មែរ/អង់គ្លេស/បារាំង
ចំណាត់ថ្នាក់ឯកសារ៖ សាធារណៈ

# សេចក្តីសម្រេចលើសេចក្តីជូនដំណឹងពីរនៃបណ្តឹងសាទុក្ខដែលដាក់ ដោយ អៀង សារី

00660498

002/19-09-2007-អ.វ.ត.ក/អ.ជ.ស.ជ/អ.ជ.ត.ក

ឯកសារលេខ.**E9/7/1/1/1/4**

**អង្គជំនុំជម្រះតុលាការកំពូល** នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា(“**អ.វ.ត.ក**”)៖

**បានទទួល** សេចក្តីជូនដំណឹងពីរនៃបណ្តឹងសាទុក្ខ ដែលដាក់ដោយសហមេធាវីការពារក្តីជនជាប់ចោទ (“សហមេធាវី”), អៀង សារី (“សេចក្តីជូនដំណឹងនៃបណ្តឹងសាទុក្ខ”);[1]

**កត់សំគាល់លើចម្លើយតបរួមដែលដាក់ដោយសហព្រះរាជអាជ្ញាទៅនឹងសេចក្តីជូនដំណឹង** នៃបណ្តឹងសាទុក្ខដែលសហព្រះរាជអាជ្ញាស្នើសុំអង្គជំនុំជម្រះសម្រេចថា សេចក្តីជូនដំណឹងនៃបណ្តឹងសាទុក្ខនេះ មិនអាចទទួលយកបាន ហើយ**បង្គាប់** សហមេធាវីការពារក្តី មិនឲ្យដាក់សារណាបន្ថែមទៀតទាក់ទងនឹងសេចក្តីជូនដំណឹងនៃបណ្តឹងសាទុក្ខនេះ[2]។

**ពិចារណាឃើញថា** សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង[3]ដែលសហមេធាវីការពារក្តី មានបំណងធ្វើបណ្តឹងសាទុក្ខប្រឆាំងនោះ នៅក្នុងសេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ មិនស្ថិតក្នុងយុត្តាធិការ

---

[1] សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការដំបូងដែលមានចំណងជើងថាផ្នែកសម្រេចសេចក្តីរបស់អង្គជំនុំជម្រះសាលាដំបូងលើសំណើសុំពន្យាពេលកាលបរិច្ឆេទ (E9/7 និង E9/4/9), សំណុំរឿង 002/19-09-2007-អ.វ.ត.ក-អ.ជ.ស.ជ /អ.ជ.ត.ក(03), ថ្ងៃទី2 ខែមីនា ឆ្នាំ2011, E9/7/1/1; សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខរបស់ អៀង សារីប្រឆាំងនឹងដីការបង្គាប់ឲ្យមេធាវីការពារក្តី អៀង សារី ឲ្យដាក់អញ្ញត្រកម្មបឋមសំណុំរឿង 002/19-09-2007-អវតក- អ.ជ.ស.ជ / អ.ជ.ត.ក (05), ថ្ងៃទី09 ខែមីនា ឆ្នាំ2011, E51/5/5។

[2] ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខពីររបស់ អៀង សារី ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង បដិសេធការពន្យាពេលនិងការកំណត់ទំព័រដាក់អញ្ញត្រកម្ម ថ្ងៃទី18 ខែមីនា ឆ្នាំ2011, E9/7/1/1/1/1, កថាខណ្ឌ 13។

[3] ផ្នែកសម្រេចសេចក្តីរបស់អង្គជំនុំជម្រះសាលាដំបូងលើសំណើសុំពន្យាពេលកាលបរិច្ឆេទ (E9/7 និង E9/4/9), ថ្ងៃទី1 ខែមីនា ឆ្នាំ2011, E9/7/1; ដីកាបង្គាប់មេធាវីការពារក្តីអៀងសារី ដាក់អញ្ញត្រកម្ម នៅថ្ងៃទី28 ខែកុម្ភៈ ឆ្នាំ2011, E51/5/4 សេចក្តីសម្រេចលើសេចក្តីជូនដំណឹងពីរនៃបណ្តឹងសាទុក្ខដែលដាក់ដោយអៀង សារី

00660499



កំណត់របស់អង្គជំនុំជម្រះសំរាប់បណ្ដឹងសាទុក្ខ ដោយអនុលោមតាមវិធាន១០៤(៤)(វិសោធនកម្មលើកទី៧)[4] នោះទេ។

**យោងតាមសំអាងហេតុខាងលើ អង្គជំនុំជម្រះតុលាការកំពូល៖**

**សម្រេច**បដិសេធសេចក្ដីជូនដំណឹងបណ្ដឹងសាទុក្ខជាអាសារបង់ និង

**សម្រេចថា** វាមិនមានភាពចាំបាច់ក្នុងការពិចារណាលើសារណាបណ្ដឹងសាទុក្ខបន្ថែមទៀតរបស់សហមេធាវីការពារក្ដីឡើយ[5]។

**រាជធានីភ្នំពេញ ថ្ងៃទី០៨ ខែមេសា ឆ្នាំ២០១១**

**ប្រធានអង្គជំនុំជម្រះតុលាការកំពូល**

**គង់ ស្រឹម**

---

[4] សេចក្ដីសម្រេចស្ដីពីបណ្ដឹងសាទុក្ខដែលដាក់ដោយមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី (ក្រុម២ និង៣) ប្រឆាំងនឹងសេចក្ដីសម្រេចផ្ទាល់មាត់របស់អង្គជំនុំជម្រះសាលាដំបូង នៅថ្ងៃទី២៧ ខែសីហា ឆ្នាំ២០០៩, ថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០០៩, E169/1/2, កថាខណ្ឌ ៨-១២។

[5] ការឆ្លើយតបរបស់ អៀង សារីទៅនឹងចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសេចក្ដីជូនដំណឹងពីរនៃបណ្ដឹងសាទុក្ខរបស់អៀង សារី ប្រឆាំងទៅនឹង សេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងបដិសេធការពន្យាពេល និងការកំណត់ទំព័រសំរាប់ដាក់អញ្ញត្រកម្ម នៅថ្ងៃទី២២ ខែមីនា ឆ្នាំ២០១១, E9/7/1/1/1/2; បណ្ដឹងសាទុក្ខរបស់អៀង សារីប្រឆាំងនឹងការសម្រេចសេចក្ដីលើសំណើសុំពន្យាពេលកាលបរិច្ឆេទ(E9/7 និងE9/4/9) នៅថ្ងៃទី ២១ ខែមីនា ឆ្នាំ២០១១, E9/7/1/1/1/3; បណ្ដឹងសាទុក្ខរបស់អៀង សារីប្រឆាំងនឹងដីកាបង្គាប់មេធាវីការពារក្ដីអៀងសារីឲ្យដាក់អញ្ញត្រកម្ម, ថ្ងៃទី២២ ខែមីនា ឆ្នាំ២០១១, E51/6/1/1/1។